# របាយការណ៍
# ស្ដីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៦

របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

(៣០/១១/២០០៥-០៥/១២/២០០៦)

## I / សភាពការណ៍គ្រឿងញៀននៅកម្ពុជា :

ឆ្នាំ២០០៦នេះ កម្ពុជានៅតែបន្តទទួលរងឥទ្ធិពលគ្រឿងញៀនដែលកំពុងកើតមាននៅក្នុងតំបន់និងអន្តរជាតិ ជាពិសេសពីតំបន់ត្រីកោណមាស ។ ពួកឧក្រិដ្ឋជនគ្រឿងញៀននៅតែបន្តប្រើប្រាស់កម្ពុជាធ្វើជាកន្លែងចរាចរឆ្លងកាត់គ្រឿងញៀនគ្រប់ប្រភេទ ។

### ១.ការផលិត ការដាំដុះ ការចរាចរ គ្រឿងញៀន :

**ក/ កញ្ឆា :** កម្ពុជាទទួលបានជោគជ័យលើសកម្មភាពប្រឆាំងការដាំដុះនិងការជួញដូរកញ្ឆា ។ ទូទាំងប្រទេសយើងបានបន្តចលនាស្រាវជ្រាវនិងបំផ្លាញចោលស្ទើរតែឈានទៅលុបបំបាត់ទាំងស្រុងនូវការលបលួចដាំដុះនិងការជួញដូរកញ្ឆាតាមគ្រប់រូបភាព ។

**ក្រាហ្វិកផ្ទៃដីដាំដុះកញ្ឆា (ម៉ែត្រក្រឡា)**




**ខ/ គ្រឿងញៀនសំយោគ** ATS **:**

ឆ្នាំនេះ គ្រឿងញៀនសំយោគATS នៅតែបន្តកើនឡើង និងហូរពីតំបន់ត្រីកោណមាសចូលមកកម្ពុជាតាមច្រកនៃបណ្ដាខេត្តភាគខាងជើងនិងឥសានប្រទេស ។ មួយផ្នែកធំនៃគ្រឿងញៀននេះ បាននាំឆ្លងកាត់កម្ពុជាទៅកាន់ប្រទេសជិតខាងនិងទីផ្សារគ្រឿងញៀនអន្តរជាតិ ។

ទន្ទឹមនោះ ក៏បានលេចឡើងនូវការផលិតមេតំហ្វេតាមីនក្លែងក្លាយនៅក្នុងស្រុក ។ ជាក់ស្តែង មន្ត្រីអនុវត្តច្បាប់ធ្វើការបង្ក្រាបទីតាំងផលិតលួចលាក់ចំនួន៨កន្លែង ដោយរឹបអូសបានពុម្ពកែឆ្នៃចំនួន៣៩ពុម្ព (ពុម្ពមួយចំនួនមានលក្ខណៈស្វ័យប្រវត្តិជាងករណីមុនៗ) និងបានលេចឡើងនូវការចរាចរឆ្លងកាត់នូវប្រភេទមេតំហ្វេតាមីន ICE ។

**ក្រាហ្វិក មេតំហ្វេតាមីន(គ្រាប់)**




**គ/ ហេរ៉ូអ៊ីន :** នៅតែបន្តហូរចូលពីតំបន់ត្រីកោណមាសមកកម្ពុជាតាមច្រកផ្លូវគោក និងតាមដងទន្លេមេគង្គ នៃបណ្តាខេត្តភាគខាងជើងនិងឥសានប្រទេស ហើយផ្លាស់ប្តូរការវេចខ្ចប់អោយមានលក្ខណៈងាយស្រួលលាក់បាំងពីការត្រួតពិនិត្យរបស់សមត្ថកិច្ច បន្ទាប់មកនាំបន្តទៅកាន់ប្រទេសទីបី.... ។

**ក្រាហ្វិក ហេរ៉ូអ៊ីន (គីឡូក្រាម)**




**ឃ/ កូកាអ៊ីន :** ភាគច្រើនត្រូវបានពួកឧក្រិដ្ឋជនគ្រឿងញៀនប្រើប្រាស់កម្ពុជា ធ្វើជាផ្លូវចរាចរឆ្លងកាត់ដោយនាំចូលតាមផ្លូវអាកាស និងនាំចេញទៅក្រៅប្រទេសវិញតាមផ្លូវគោក ។ ថ្មីៗនេះ កូកាអ៊ីនដែលនាំមកពីអ៊ឺរុបត្រូវបានពួកឧក្រិដ្ឋជនគ្រឿងញៀនដឹកជញ្ជូនដោយលេបទុកក្នុងពោះ ហើយត្រូវបានមន្ត្រីអនុវត្តច្បាប់កម្ពុជាសហការជាមួយស្ថាប័ន DEA អាមេរិកបង្ក្រាបបានជាបន្តបន្ទាប់ ។

## ក្រាហ្វិក កូកាអ៊ីន (គីឡូក្រាម)




ក្រៅពីប្រភេទគ្រឿងញៀនខាងលើ កម្ពុជាក៏កំពុងប្រឈមមុខនឹងបាតុភាពនៃការចរាចរនូវសារធាតុគីមីផ្សំមួយចំនួនដែលអាចបង្វែរទៅផលិតគ្រឿងញៀនផងដែរ ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាននឹងកំពុងយកចិត្តទុកដាក់ជាមួយបណ្ដាប្រទេសក្នុងតំបន់ និង អន្តរជាតិ ដើម្បីត្រួតពិនិត្យបញ្ហានេះ ។

## II/**លទ្ធផលនៃកិច្ចប្រតិបត្តិការ** :

**ក -<u>ការងារបង្ក្រាបបទល្មើសគ្រឿងញៀន</u>** :

•បទល្មើសគ្រឿងញៀនសរុបមានចំនួន **៣១៤**ករណី(ឆ្នាំ២០០៥មាន ៣៦៦ករណី) ថយចុះ១៤,២០% ។

•ជនល្មើសសរុបមានចំនួន**៦១២**នាក់(ឆ្នាំ២០០៥មាន៧០៩នាក់)ថយចុះ១៣,៦៨%។

ជនល្មើសទាំង៦១២នាក់នេះបាន :

-ធ្វើការអប់រំ ១៧៨ នាក់ (ប្រុស ១២០ នាក់, ស្រី ៥៨ នាក់)

-បញ្ជូនទៅតុលាការ ៤៣៤ នាក់ គឺ ,

**ករណីមេតំហ្វេតាមីនគ្រាប់** :

•សរុបមានចំនួន ២៨៣ ករណី(ឆ្នាំ២០០៥មាន៣៦៦ករណី) ថយចុះ២២,៦៧%

•រឹបអូសមេតំហ្វេតាមីនគ្រាប់ចំនួន៤២៨.៥៥៣គ្រាប់(ឆ្នាំ២០០៥មាន៣៣៨.៦៥៥គ្រាប់) កើនឡើង ២៦,៥៤% និង មេតំហ្វេតាមីនICE ៣,៨១២គ.ក្រ + ៥៤៨កូនកញ្ចប់, មេតំហ្វេតាមីនម្សៅ ៤០៤,៤០ក្រាម ។

•ឃាត់ខ្លួនជនល្មើស **៥៥៧**នាក់ ក្នុងនោះ

-ធ្វើការអប់រំ ១៦៤ នាក់ (ស្រី ៥២ នាក់)

-បញ្ជូនទៅតុលាការ ៣៩៣ នាក់ គឺ :

ខ្មែរ ៣៦៥ នាក់ (ស្រី ៧៧ នាក់)

វៀតណាម ២០ នាក់ (ស្រី ១១ នាក់)

ឡាវ ២ នាក់ (ប្រុស)

អាមេរិក ១ នាក់ (ប្រុស)

នីហ្សេរីយ៉ា ១ នាក់ (ប្រុស)

ថៃ ៤ នាក់ (ស្រី ២ នាក់)

**-ករណីមេតំហ្វេតាមីន** ICE :

•បង្ក្រាបបាន ១ករណី, បញ្ជូនទៅតុលាការ ៣នាក់ប្រុស (ជនជាតិម៉ាឡេស៊ី)

•រឹបអូសមេតំហ្វេតាមីន ICE ចំនួន ១២,៤០០ គ.ក្រ ។

**-ករណី ហេរ៉ូអ៊ីន :**

•បង្ក្រាបបាន ១៨ករណី (ឆ្នាំ២០០៥មាន ៩ករណី) កើនឡើង៥០%

•រឹបអូសហេរ៉ូអ៊ីនចំនួន ១៩,៥២១ គ.ក្រ (ឆ្នាំ២០០៥មាន ៨,៩៦០ គ.ក្រ) កើនឡើង៥៤,១០% និង៥១កូនកញ្ចប់

•ឃាត់ខ្លួនជនល្មើស ២៨ នាក់ (ឆ្នាំ២០០៥មាន ១០នាក់) កើនឡើង៦៤,២៨%

-ធ្វើការអប់រំ ៣ នាក់ (ស្រី ១ នាក់)

-បញ្ជូនទៅតុលាការ ២៥ នាក់ គឺ :

ខ្មែរ សរុប ៧ នាក់ (ប្រុស ៦ នាក់, ស្រី ១ នាក់)

អាមេរិក សរុប ១ នាក់(ប្រុស)

ចិនតៃវ៉ាន់ សរុប ៩ នាក់ (ប្រុស ៧ នាក់, ស្រី ២ នាក់)

ថៃ សរុប ២ នាក់(ប្រុស)

វៀតណាម សរុប ៦ នាក់ (ប្រុស ២ នាក់, ស្រី ៤ នាក់)

**-ករណី កូកាអ៊ីន :**

•បង្ក្រាបបាន ៥ ករណី (ឆ្នាំ២០០៥មាន ១ករណី)

•រឹបអូសកូកាអ៊ីនចំនួន ៥,១៣៣ គ.ក្រ (ឆ្នាំ២០០៥មាន ១ គ.ក្រ)

•ឃាត់ខ្លួនជនល្មើស ១១ នាក់ (ឆ្នាំ២០០៥មាន ១ នាក់)

-ធ្វើការអប់រំ ២ នាក់ (ប្រុស)

-បញ្ជូនទៅតុលាការ ៩ នាក់ គឺ :

ហ្គាណា ១ នាក់(ប្រុស)

អេក្វាឌ័រ ១ នាក់(ប្រុស)

ប៉េរូ ៥ នាក់(ស្រី១នាក់)

ថៃ ១ នាក់(ស្រី)

ខ្មែរ ១ នាក់(ប្រុស)

**-ករណី ដាំដុះកញ្ឆា :**

- បង្ក្រាបបាន ៥ ករណី
- បំផ្លាញកញ្ឆាលើផ្ទៃដីចំនួន ១៤៣,៤ ម$^{២}$ និង ១.២០០ គុម្ពកញ្ឆា
- ឃាត់ខ្លួនជនល្មើស **៨** នាក់

-ធ្វើការអប់រំ ៥ នាក់(ស្រី១នាក់)

-បញ្ជូនទៅតុលាការ ៣ នាក់ ប្រុស ជនជាតិខ្មែរ

**-ករណី ចាប់តាមដីកាតុលាការ :** **១** ករណី / **១** នាក់ ជនជាតិខ្មែរ(ប្រុស) ។

ក្រៅពីករណីបង្ក្រាប :

-ស្នងការនគរបាលខេត្តបាត់ដំបង ស្នាក់ចាប់ប្រេងម្រះព្រៅបានចំនួន៥៧០លីត្រ។

-មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើការ-វិភាគលើសំណាកវត្ថុតាងគ្រឿងញៀន សរុបបានចំនួន **៣៦៩ សំណាក** ។ ក្នុងនោះ ,

-អវិជ្ជមានសារធាតុញៀនចំនួន **៤១ សំណាក** ។

-វិជ្ជមានសារធាតុញៀនចំនួន **៣២៨ សំណាក** គឺ :

| | | | |
|---|---|---|---|
| ប្រភេទមេតំហ្វេតាមីនICE | ចំនួន | ៤៥ | សំណាក |
| ប្រភេទមេតំហ្វេតាមីន គ្រាប់ | ចំនួន | ២៥០ | សំណាក |
| អ៊ិចស្តាស៊ី(MDMA) | ចំនួន | ៣ | សំណាក |
| ហេរ៉ូអ៊ីន | ចំនួន | ១៧ | សំណាក |
| កូកាអ៊ីន | ចំនួន | ៨ | សំណាក |
| កេតាមីន | ចំនួន | ៥ | សំណាក |

-តាមរយៈស្ថិតិផ្តល់ដោយស្នងការនគរបាលខេត្ត-ក្រុង ក្តាប់បានពីអ្នកប្រើប្រាស់គ្រឿងញៀនឆ្នាំនេះសរុបមានចំនួន**៦.៥០០**នាក់ (តួលេខរបស់មន្ទីរប្រឆាំងគ្រឿងញៀន) ប្រៀបឆ្នាំ២០០៥ ថយចុះ ៨,១១% ។

| លំដាប់ឆ្នាំ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
|---|---|---|---|---|---|---|---|
| ចំនួនអ្នកប្រើគ្រឿងញៀន | ៥៩១ | ៩២៩ | ២.៧៥០ | ៤.៣៨៧ | ៥.៥០២ | ៧.០៧៤ | ៦.៥០០ |
| ភាគរយកើន/ថយ | | កើន ៥៧% | កើន១៩៦% | កើន ៥៩% | កើន ២៥% | កើន ២៨% | **ថយ ៨,១១%** |

ក្រៅពីកិច្ចប្រតិបត្តិការខាងលើ អនុវត្តសាលក្រមតុលាការ និងដើម្បីអបអរសាទរ ក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំនេះ :

-ខេត្តក្រចេះ បានដុតបំផ្លាញមេតំហ្វេតាមីនចំនួន **៥៥៩.៩០៥**គ្រាប់ និង ហេរ៉ូអ៊ីន ចំនួន **២,៤** គ.ក្រ ។

-ខេត្តបាត់ដំបង បានដុតបំផ្លាញ ហេរ៉ូអ៊ីន **៤** កូនកញ្ចប់ និង មេតំហ្វេតាមីន ចំនួន **៧២.៨២៣** គ្រាប់ ។

-សាលាក្រុងភ្នំពេញ បានដុតបំផ្លាញមេតំហ្វេតាមីន និង អ៊ិចស្តាស៊ី **២០៨.៧៨១** គ្រាប់, ថ្នាំញៀនម្សៅគ្រប់ប្រភេទចំនួន **២២,៧៣** គ.ក្រ ។

**ខ-ការងារបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ :**

ដើម្បីពង្រឹងប្រសិទ្ធិភាពអនុវត្តច្បាប់ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន :

-បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយកុំព្យូទ័រជាមូលដ្ឋាន(CBT.Computer Based Training), ឧទ្ទេសនាមពីនីតិវិធីវេចខ្ចប់ /រក្សាទុកវត្ថុតាងគ្រឿងញៀន, បណ្តុះបណ្តាលបច្ចេកទេសស៊ើបអង្កេត, ផ្សព្វផ្សាយលើកកំពស់ការយល់ដឹងអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន...នៅមន្ទីរប្រឆាំងគ្រឿងញៀន, ក្រុងព្រះសីហនុ, បាត់ដំបង, សៀមរាប, បន្ទាយមានជ័យ(ស្រុកសិរីសោភ័ណ្ឌ-អូរជ្រៅ), កំពង់ចាម និងនៅសាលាភូមិន្ទនគរបាលជាតិ សរុបទាំងអស់ ២.៦២៤ នាក់ ។

-សហការជាមួយUNODC រៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន ( BLO. Border Liasion Office) នៅ**ប្រកជួង**(ខេត្តបាត់ដំបង) និង**ប្រកព្រំ**(ក្រុងប៉ៃលិន) ចំនួនពីរបន្ថែមទៀត(សរុបទាំងអស់មាន៩កន្លែង) ។

-បណ្តុះបណ្តាលពីរបៀបថែទាំ និងប្រើប្រាស់ម៉ាស៊ីនវិភាគគ្រឿងញៀន GC-MS ដែលជាជំនួយរបស់ស្ថានទូតបារាំង ។

**គ-ការងារសរសើរ និង លើកទឹកចិត្ត :**

-អគ្គលេខាធិការដ្ឋាន បានប្រគល់ វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាជូនដល់កម្ម-សិក្សាការី របស់អង្គការ "ឌីរ៉ក់" ចំនួន១០២នាក់ ។

-ជូនប័ណ្ណសរសើរ និង ឧបត្ថម្ភថវិកាលើកទឹកចិត្តចំនួនពីរលានរៀល ដល់មន្ទីរប្រឆាំងគ្រឿងញៀនដែលមានស្នាដៃបង្ក្រាបបទល្មើសគ្រឿងញៀនធំៗចំនួន១៧ករណី ។

-ឧបត្ថម្ភដល់សាលាខេត្តកោះកុង ដើម្បីរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទ្វេភាគីកោះកុង-ត្រាត លើកទី១០ ចំនួនពីរលានរៀល ។

-ផ្តល់មេដាយ សហមេត្រីថ្នាក់សេនា ចំនួន១ ដល់សេនានុព័ន្ធប៉ូលីសបារាំង និង មេដាយសហមេត្រីថ្នាក់អស្សប្ញទ្ធិ ចំនួន២ ដល់អនុសេនានុព័ន្ធប៉ូលីសនិងអ្នកសំរបសំរួលគំរោងគាំទ្រនីតិរដ្ឋ នៃស្ថានទូតបារាំងប្រចាំនៅកម្ពុជា ។

**ឃ-ការងារអប់រំ បង្ការ និង ការពារ :**

-បានចុះអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការលើកកំពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន និង ការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ដែលបណ្តាលពីការប្រើបំពានគ្រឿងញៀន ជាមួយអង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ (KHANA) ។ ផ្តើមចេញពីអនុស្សារណៈនៃការយោគយល់គ្នានេះ អង្គការKHANA បានជួយផលិតសៀវភៅច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន ៣.០០០ ច្បាប់ និង កំពុងសហការអនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយជាច្រើនទៀត ។

-បានផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីអចិន្ត្រៃយ៍ ដែលឧបត្ថម្ភដោយប្រព័ន្ធផ្សព្វផ្សាយជាតិនិងឯកជន ស្តីពីបញ្ហាគ្រឿងញៀន ។

-បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ, អង្គការUNODC, អង្គការអន្តរជាតិ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តក្រុង, អង្គការក្រៅរដ្ឋាភិបាលនានា... ដើម្បីចលនាឱ្យមានការចូលរួមពី ព្រះសង្ឃ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស នគរបាល យោធា បុគ្គលិកមជ្ឈមណ្ឌលព្យាបាល ដើម្បីអនុវត្តកម្មវិធីលើកកំពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់, អំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន និង ការងារព្យាបាល/ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-ក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំនេះ អាជ្ញាធរជាតិបានបំផុសបណ្តាខេត្ត-ក្រុងអោយចូលរួមប្រារព្ធយ៉ាងផុលផុស ដោយមានព្រះសង្ឃ ប្រជាជន/មហាជន ចូលរួមប្រមាណជាង២០.០០០នាក់ ។

-ក្នុងពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ អកអំបុក ក្រសួង-ស្ថាប័នរដ្ឋពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ បានចូលរួមយ៉ាងសកម្មលើការងារអប់រំផ្សព្វផ្សាយ ក្នុងនោះអាជ្ញាធរអេដស៍បានអនុវត្តកម្មវិធីផ្ដល់ស្រោមអនាម័យ ១៣០.០០០ ស្រោម, អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចែកខិត្តប័ណ្ណជាង ២០.០០០ សន្លឹក, ហើយអង្គការUNODC, KHANA, WHO, មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា បានចែកចាយឯកសារផ្សព្វផ្សាយជាច្រើនទៀត ។

-បានផ្ដល់ការគាំទ្រចំពោះអង្គការចំនួនបីគឺ អង្គការមិត្តសំឡាញ់, អង្គការកសាង និង សមាគមអភិវឌ្ឍន៍កសិករនិងសិទ្ធិមនុស្សយុវជនខ្មែរ ដែលបានស្នើសុំចាប់ផ្ដើមអនុវត្ត និងបន្តអនុវត្តកម្មវិធីប្តូរម្ជុលសឺរ៉ាំង និង កម្មវិធីផ្សព្វផ្សាយអប់រំនិងបង្ការអំពីបញ្ហាគ្រោះថ្នាក់នៃគ្រឿងញៀន, ការព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀន, វេទិកាសាធារណៈ, ការអង្កេតអំពីការជួញដូរគ្រឿងញៀន ។

-បានសហការជាមួយអង្គការមូលនិធិអាស៊ី ក្នុងការធ្វើការប៉ាន់ប្រមាណស្ដីពីការប្រើប្រាស់សារធាតុញៀនក្នុងចំណោមកុមារ និង ស្ត្រីដែលរងគ្រោះដោយការជួញដូរ ។

-សិក្ខាសាលានៅខេត្តសៀមរាប ស្ដីពីសារៈសំខាន់នៃការបង្ការជាសកលសំរាប់អ្នកផ្ដល់សេវា ដើម្បីដោះស្រាយបញ្ហាប្រើបំពានគ្រឿងញៀននិងអេដស៍នៅមន្ទីរឃុំឃាំង ។

-បានចូលរួមសិក្ខាសាលាស្ដីពីជំងឺអេដស៍ និងផលវិបាកបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀននៅក្នុងពន្ធនាគារ ដែលរៀបចំដោយអង្គការ UNODC -WHO នៅទីស្ដីការក្រសួងមហាផ្ទៃ ។

**ង-<u>ការងារព្យាបាល និង ស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន</u> :**

-បានចុះទៅពិនិត្យនិងជំរុញលើកទឹកចិត្តលើការងារ អប់រំកែប្រែអ្នករងគ្រោះដោយគ្រឿងញៀននៅមជ្ឈមណ្ឌលបន្សាបជាតិញៀនក្នុងស្រុកបវេល /មជ្ឈមណ្ឌលរបស់កងរាជអាវុធហត្ថខេត្តបាត់ដំបង និងមជ្ឈមណ្ឌលរបស់កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ។

-បានចូលរួមរៀបចំគំរោងស្នើសុំថវិកាសំរាប់អនុវត្តសកម្មភាពនានា ក្នុងការកាត់បន្ថយគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀនពីមូលនិធិសកលសំរាប់ការប្រយុទ្ធនឹងជម្ងឺអេដស៍ / របេង / គ្រុនចាញ់ជុំទី៦ ។

-បានពិភាក្សាជាមួយអង្គការសុខភាពពិភពលោក(WHO) ក្នុងការអនុវត្តន៍គំរោងទប់ស្កាត់ការរីករាលដាលជម្ងឺអេដស៍បណ្ដាលមកពីការប្រើបំពានគ្រឿងញៀន ។

-ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា បានបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា១កន្លែងនៅខេត្តបន្ទាយមានជ័យឈ្មោះ“មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់”។

**ច-ការងារនីតិកម្ម និង ផែនការ :**

ក្នុងឆ្នាំ២០០៦នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបើកសម័យប្រជុំរបស់ខ្លួនចំនួន២លើកគឺ លើកទី៧នៅថ្ងៃទី១៤/៣/២០០៦ និង លើកទី៨នៅថ្ងៃទី១៣/៩/២០០៦ ដើម្បីពិនិត្យលើលទ្ធផលការងារហើយជារួមគឺសំរេចបាននូវ :

-សារាចររបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តវិធានការអប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-ព្រះរាជក្រឹត្យស្តីពីការកែសំរួលព្រះរាជក្រឹត្យ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-ផែនការសកម្មភាពជាតិឆ្នាំ២០០៧ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-សេចក្តីណែនាំ ស្តីពីគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន របស់ អ.ជ.ប.គ.ញ ។

-ប្រកាសស្តីពី “នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និង ការញុះញង់ឱ្យលក់ដោយខុសច្បាប់” របស់ក្រសួងយុត្តិធម៌ ។

-សេចក្តីសំរេចលេខ០០៧/០៦សសរ/អជបគញ ចុះថ្ងៃទី០៤ខែកក្កដាឆ្នាំ២០០៦ស្តីពី “ការបង្កើតក្រុមការងារអន្តរក្រសួងសំរាប់រៀបចំប្រកាសស្តីអំពី ក្បួនអនុវត្តនីតិវិធីនៃការដកយកសំណាក ការវេចខ្ចប់ និងការថែរក្សាវត្ថុតាងគ្រឿងញៀនឱ្យមានសុវត្ថិភាព ។

-ការបង្កើតគណៈកម្មការក្នុងការបើកកញ្ចប់សំណាកគ្រឿងញៀន មុនធ្វើកោសល្យវិច័យ និងការរក្សាទុកសំណាកគ្រឿងញៀនដែលនៅសល់ក្រោយពេលធ្វើកោសល្យវិច័យក្នុងអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-ការដាក់បញ្ចូលការងារត្រួតពិនិត្យគ្រឿងញៀន ទៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធ-សាស្ត្រថ្នាក់ជាតិ ។

**ឆ-លទ្ធផលនៃកិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិ :**

**-កិច្ចប្រជុំថ្នាក់ជាតិ :**

-ទស្សនកិច្ចរបស់ឯកឧត្តម Antonio Maria COSTA អគ្គលេខាធិការរងនៃអង្គការ

សហប្រជាជាតិ បានចូលជួបសំដែងការគួរសមជាមួយប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងស្វែងយល់ពីបញ្ហាគ្រឿងញៀននៅកម្ពុជា ។ ឯកឧត្តមបានវាយតំលៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងបានគាំទ្រចំពោះការបន្តគំរោងស្តីពីការពង្រឹងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយអង្គការ UNODC ។

-ក្នុងកិច្ចប្រជុំ Minidublin Group បណ្តាប្រទេសសមាជិកទាំងអស់បានសន្យានឹងបន្តយន្តការគាំទ្រនយោបាយក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនដល់កម្ពុជា ។

**-កិច្ចប្រជុំថ្នាក់តំបន់ :**

-សន្និសីទអន្តរជាតិ (ADEC. **A**sia-Pacific **D**rug **E**nforcement **C**onference ) លើកទី១១ ស្តីពីបញ្ហាគ្រឿងញៀននៅតំបន់អាស៊ី / ប៉ាស៊ីហ្វិក (ជប៉ុន) ។

-សម័យប្រជុំលើកទី៤៩នៃគណៈកម្មការគ្រឿងញៀនអង្គការអន្តរជាតិ (វីយែន) ។

-សន្និសីទកាសែតអន្តជាតិស្តីពីការដុតបំផ្លាញគ្រឿងញៀននៅរដ្ឋសាន (ភូមា) ។

-កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន (ASOD. **A**sia **S**enior **O**fficials on **D**rug Matters ) ស្តីពីបញ្ហាគ្រឿងញៀន (ប្រទេសថៃ) ។

-កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន+ចិន-កូរ៉េ-ជប៉ុន ស្តីពីឧក្រឹដ្ឋកម្មឆ្លងដែនដែលពាក់ព័ន្ធបញ្ហាគ្រឿងញៀន (SOMTC / A**S**EAN Senior **O**fficials **M**eeting on **T**ransnational **C**rime ) ។

-វគ្គហ្វឹកហ្វឺនស្តីពី "ការកសាងកម្លាំងបង្កប់ និង បច្ចេកទេសនៃកិច្ចប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន" ហ្សាការតា ។

-វគ្គសិក្សាស្តីពី "ការត្រួតពិនិត្យនិងការប្រើបំពានគ្រឿងញៀន" នៅ (ជប៉ុន) ។

-កិច្ចប្រជុំថ្នាក់តំបន់ លើកទី២ ស្តីពីការអង្កេតប្រេងម្រះព្រៅ (កូឡាឡំពួរ) ។

-កិច្ចប្រជុំក្រុមកិច្ចសហប្រតិបត្តិការអាស៊ី ស្តីពីការគ្រប់គ្រងនិងការបង្វែរសារធាតុគីមីផ្សំ (ប្រទេសអូស្ត្រាលី) ។

**-កិច្ចប្រជុំគំរោងរបស់តំបន់ :**

-សិក្ខាសាលាគំរោងH84 ស្តីពី "ការបង្កើតប្រព័ន្ធព័ត៌មានទីផ្សារសំរាប់ផលិតផលដែលបានពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ដំណាំជំនួស" (ភូមា) ។

-សន្និសីទស្តីពីការអប់រំបង្ការបញ្ហាគ្រឿងញៀន (ហ្វីលីពីន) ។

-សិក្ខាសាលាអន្តរជាតិស្តីពីការត្រួតពិនិត្យដំណាំគ្រឿងញៀនខុសច្បាប់ (ថៃ) ។

-សិក្ខាសាលាគំរោង I 09 ស្តីពីការពង្រឹងការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងការថែទាំអ្នកផ្ទុកមេរោគអេដស៍ / ជំងឺអេដស៍ ក្នុងចំណោមអ្នកប្រើគ្រឿងញៀន និងអ្នកជាប់ពន្ធនាគារ (បាងកក) ។

-កិច្ចប្រជុំស្តីពី "ការផ្តល់នូវជំនាញចាំបាច់ចំពោះអ្នកប្រើគ្រឿងញៀនដែលត្រូវបានផ្តាច់និងអ្នកផ្ទុកមេរោគអេដស៍ ដើម្បីធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញ (គំរោងI09) នៅទីក្រុងបាលីឥណ្ឌូនេស៊ី ។

-វគ្គបណ្តុះបណ្តាលបច្ចេកទេសស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុប្រឆាំងការសំអាតប្រាក់។

-វគ្គសិក្សាស្តីពី "ការត្រួតពិនិត្យសារធាតុគីមីផ្សំ" សំរាប់មន្ត្រីអនុវត្តច្បាប់គ្រឿងញៀនអាស៊ាន (ប្រទេសថៃ) ។

-កិច្ចប្រជុំគំរោង (F97) ស្តីពីការធ្វើឱ្យប្រសើរនូវទិន្នន័យនិងប្រព័ន្ធព័ត៌មានគ្រឿងញៀន ។

**-កិច្ចប្រជុំត្រីភាគី :**

-កិច្ចប្រជុំត្រីភាគី (កម្ពុជា-ឡាវ-វៀតណាម) លើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (វៀតណាម) ។

**-កិច្ចសហប្រតិបត្តិការ ទ្វេភាគី :**

**-កម្ពុជា-**UNODC :

-បានឯកភាពលើគំរោងស្តីពី ការពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋាន និងការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា (J 11) រយៈពេល៣ឆ្នាំ ។

-បានចុះហត្ថលេខាលើគំរោង I 61 សំរាប់រយៈពេល១ឆ្នាំ ដើម្បីបន្តពីគំរោងស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន (គំរោងAD/RAS/D91) ។

**-កម្ពុជា-ថៃ :** ការិយាល័យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនថៃ ( ONCB. **O**ffice of the **N**arcotics **C**ontrol **B**oard) បាន :

១-ជួយបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់នៅខេត្តជាប់ព្រំដែន (ពោធិសាត់ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ) ។

២-ផ្តល់រថយន្ត១គ្រឿង, កុំព្យូទ័រ, ម៉ាស៊ីនថត, តេស្តគ្រឿងញៀន សំរាប់បំរើការងារត្រួតពិនិត្យគ្រឿងញៀន ។

៣-ផ្តល់លទ្ធភាពឱ្យកម្ពុជាធ្វើទស្សនកិច្ចសិក្សាដកពិសោធន៍លើ ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមសហគមន៍នៅក្នុងប្រទេសថៃ ។

៤-កិច្ចប្រជុំទ្វេភាគី(កម្ពុជា-ថៃ)លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន(សៀមរាប ២៧-២៨/១១/២០០៦) ។

៥-កិច្ចប្រជុំទ្វេភាគីលើកទី១០ ស្តីពី កិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន(ខេត្តកោះកុង-ត្រាត) ។

**-កម្ពុជា-ចិន :**

ខេត្តយូណាន់ បានផ្តល់ថ្នាំសំរាប់ព្យាបាលអ្នកញៀនគ្រឿងញៀន(អាភៀន) ៣០ កេះ(៣០.០០០គ្រាប់) ។ អគ្គលេខាធិការដ្ឋានបានផ្តល់ជូនក្រសួងសុខាភិបាល១៥កេះ, ក្រសួងសង្គមកិច្ច១កេះ, អង្គការស្តារយុវនីតិសម្បទាអ្នកញៀនគ្រឿងញៀន១កេះ, មណ្ឌលកែប្រែរបស់កងរាជអាវុធហត្ថខេត្តបាត់ដំបង២កេះ, មណ្ឌលស្តារនីតិសម្បទាស្រុកបវេល១កេះកន្លះ,មណ្ឌលកែប្រែរបស់កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ២កេះ, មណ្ឌលកែប្រែរបស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប១កេះ, មន្ទីរប្រឆាំងគ្រឿងញៀន១កេះកន្លះ, សាលាក្រុងភ្នំពេញ២កេះ និង ខេត្តកោះកុង១កេះ ។

**-កម្ពុជា-វៀតណាម :**

១-គណៈប្រតិភូអន្តរក្រសួងសមាជិកអ.ជ.ប.គ.ញ ទៅទស្សនកិច្ចសិក្សាដកបទពិសោធន៍លើការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន(ហូជីមិញ) ។

២-កិច្ចប្រជុំទ្វេភាគីខេត្តកំពង់ចាម-តៃនីញ(វៀតណាម) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទនិងសារធាតុគីមីផ្សំ ។

**-កម្ពុជា-ជប៉ុន :**

អគ្គលេខាធិការដ្ឋានបានចុះហត្ថលេខាលើ កំណត់ហេតុនៃកិច្ចប្រជុំក្រុមការងារវាយតំលៃបឋម ស្តីពីគំរោងត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី(កម្ពុជា-ជប៉ុន)ជាមួយអង្គការ JICA ។

**-កម្ពុជា-អាមេរិក :**

១-មន្ត្រីអនុវត្តច្បាប់ចំនួន២រូបរបស់មន្ទីរប្រឆាំងគ្រឿងញៀន ទៅចូលរួមក្នុងសិក្ខាសាលា ស្តីពីការអនុវត្តន៍ច្បាប់គ្រឿងញៀនអន្តរជាតិនៅរដ្ឋហាវៃ(អាមេរិក) ។

២-ស្ថាប័នDEA បានបណ្តុះបណ្តាលអំពីការអនុវត្តន៍ច្បាប់គ្រឿងញៀនជាមូលដ្ឋាន, កិច្ចសហប្រតិបត្តិការស្ទាក់ចាប់គ្រឿងញៀនតាមច្រកព្រលានយន្តហោះ, ការត្រួតពិនិត្យរូបីយប័ណ្ណអាមេរិកក្លែងក្លាយ (នៅកម្ពុជា) ។

៣-ការសន្យាជួយលើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងពិនិត្យឡើងវិញដើម្បីធ្វើឱ្យដំណើរការនូវមន្ទីរពិសោធន៍ដែលបានជួយពីឆ្នាំ១៩៩៩ ។

**-កម្ពុជា-បារាំង :**

ភាគីបារាំងបានផ្តល់នូវម៉ាស៊ីនវិភាគគ្រឿងញៀនមួយប្រភេទG.C-MS ដល់មន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

## III / **<u>ការសន្និដ្ឋាន</u>** :

ផ្តើមចេញពីសភាពការណ៍គ្រឿងញៀនតំបន់និងអន្តរជាតិ ក្នុងឆ្នាំ២០០៦នេះគ្រឿងញៀននៅកម្ពុជានៅតែបន្តកើនឡើង ជាពិសេសគ្រឿងញៀនសំយោគ ATS ។

**១-ការអនុវត្តន៍ច្បាប់ :**

លទ្ធផលអនុវត្តច្បាប់ក្នុងឆ្នាំ២០០៦ទទួលបានជោគជ័យ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៥ ។ ទោះបីលទ្ធផលបង្ក្រាបថយចុះទាំងចំនួនបទល្មើសនិងជនល្មើស ប៉ុន្តែបរិមាណគ្រឿងញៀនដែលរឹបអូសបានច្រើនជាងមុន ។ កត្តានេះបង្ហាញឱ្យឃើញថា :

-មន្ត្រីអនុវត្តច្បាប់គ្រឿងញៀន កាន់តែត្រូវបានលើកកំពស់ទាំងសមត្ថភាព, ទាំងផ្នែកជំនាញបច្ចេកទេស និង វិធីសាស្ត្រក្នុងការបង្ក្រាបប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

**២-លើការកាត់បន្ថយតំរូវការគ្រឿងញៀន :**

ប្រឈមមុខនឹងសភាពការណ៍គ្រឿងញៀននៅកម្ពុជា រាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបានការគាំទ្រនិងសហការពីអន្តរជាតិ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល បានធ្វើសកម្មភាពផ្សព្វផ្សាយអប់រំលើកកំពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន កាន់តែចូលជ្រៅទៅក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋ ជាពិសេសមជ្ឈដ្ឋានយុវជននិងក្រុមដែលងាយរងគ្រោះ ។

ឆ្នាំ២០០៦នេះ ស្ថិតិអ្នកប្រើបំពានគ្រឿងញៀនមានការថយចុះ ទោះបីមិនទាន់អាចវាយតម្លៃថា ទទួលបានជោគជ័យគួរអោយកត់សំគាល់ប៉ុន្តែស្ថិតិអ្នកប្រើបំពានគ្រឿងញៀនស្ថិតក្នុងស្ថានភាពមានលំនឹង(បើកើនឡើងក៏កើនតិច, បើថយចុះក៏ថយតិច) ។

រាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាននិងកំពុងពង្រឹងនិងពង្រីកសកម្មភាពព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅទូទាំងប្រទេស ។ ការងារនេះត្រូវបានទទួលការគាំទ្រនិងចូលរួមពីអន្តរជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដែលធ្វើអោយចំនួនអ្នករងគ្រោះដោយការប្រើបំពានគ្រឿងញៀនទទួលបាននូវការគាំពារ ។

ឆ្នាំ២០០៦ លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន រាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានការគាំទ្រនិងសហការពីបណ្តាប្រទេសម្ចាស់ជំនួយពីអន្តរជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលគួរអោយកត់សំគាល់ ។

កម្ពុជា កំពុងតែសកម្មរួមជាមួយអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាពិសេសអនុវត្តផែនការសកម្មភាពរបស់អាស៊ានបូកចិន ដើម្បីឈានទៅអាស៊ានគ្មានគ្រឿងញៀនឆ្នាំ២០១៥ ។

## IV / <u>ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៧</u> :

### ១-ការពង្រឹងរចនាសម្ព័ន្ធរបស់ អ.ជ.ប.គ.ញ និង ស្ថាប័នពាក់ព័ន្ធ :

១.១-លើកកំពស់សមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និង ក្រសួងស្ថាប័នពាក់ព័ន្ធ ។

១.២-ពង្រឹងប្រសិទ្ធិភាពការងាររបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាស្ថាប័នមានស្វ័យភាព រដ្ឋបាល និង ហិរញ្ញវត្ថុ ។

១.៣-ពង្រឹងបណ្តាញមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។

១.៤-បង្កើតអង្គភាពសំរាប់ធ្វើការងារត្រួតពិនិត្យគ្រឿងញៀន នៅតាមក្រសួងសមាជិក អ.ជ.ប.គ.ញ ។

១.៥-បន្តពង្រឹងនិងពង្រីកក្រុមការងារអន្តរក្រសួងសមាជិក អ.ជ.ប.គ.ញ ។

១.៦-បង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្តល់ជំនួយ និងដៃគូផ្សេងទៀតទាំងទ្វេភាគី និង ពហុភាគី ។

១.៧-ធ្វើជាសេនាធិការ ក្នុងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និង រាយការណ៍ជូនប្រធាន អ.ជ.ប.គ.ញ នូវរាល់សកម្មភាពការងាររបស់ក្រសួងសមាជិកនិងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ។

**២-ការកាត់បន្ថយតំរូវការគ្រឿងញៀនខុសច្បាប់ :**

២.១-លើកកំពស់ការយល់ដឹងជាសាធារណៈ ស្តីពីផលប៉ះពាល់នៃគ្រឿងញៀន និង ឥទ្ធិពលគ្រឿងញៀនខុសច្បាប់ទៅលើសង្គម ។

២.២-សហការជាមួយក្រសួងអប់រំយុវជននិងកីឡា ដើម្បីអភិវឌ្ឍន៍កម្មវិធីអប់រំបង្ការគ្រឿងញៀន ។

២.៣-ចូលរួមចំណែកក្នុងការដោះស្រាយ បញ្ហារីករាលដាលនៃមេរោគអេដស៍ /ជំងឺអេដស៍បណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។

២.៤-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ, អង្គការសហប្រជាជាតិ, អង្គការក្រៅរដ្ឋាភិបាល, សង្គមស៊ីវិល, អតីតអ្នកញៀន, ប្រព័ន្ធផ្សព្វផ្សាយ, បណ្តាញសាសនា និង អាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើនកិច្ចប្រតិបត្តិការអប់រំបង្ការគ្រឿងញៀន-ហ៊ីវ/អេដស៍ ចល័តនៅតាមបណ្តាចំណុចគោលដៅ ។

២.៥-ខិតខំធ្វើអោយប្រសើរឡើង នូវយន្តការត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពអប់រំបង្ការគ្រឿងញៀន ។

២.៦-សហការជាមួយដៃគូពាក់ព័ន្ធ ដើម្បីតាមដានលើអត្រា(កើនឡើង/ថយចុះ) នៃស្ថានភាពប្រើបំពានគ្រឿងញៀន និងការចម្លងមេរោគអេដស៍/ជំងឺអេដស៍ ។

**៣-ការកាត់បន្ថយដំណាំគ្រឿងញៀនខុសច្បាប់ :**

៣.១-បន្តពង្រឹងយុទ្ធនាការលុបបំបាត់ការដាំដុះដំណាំគ្រឿងញៀនខុសច្បាប់ ។

៣.២-បន្តលើកកំពស់ការយល់ដឹងជាសាធារណៈ អំពីច្បាប់ត្រួតពិនិត្យគ្រឿងញៀន ស្តីពីការដាំដុះដំណាំកញ្ឆា និង ដំណាំគ្រឿងញៀនខុសច្បាប់ផ្សេងៗទៀត ។

**៤-ត្រួតពិនិត្យ ការផលិត ការជួញដូរ គ្រឿងញៀនខុសច្បាប់ :**

៤.១-បន្តជំរុញមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់លើសកម្មភាពទប់ស្កាត់គ្រឿងញៀន ។

៤.២-ពង្រឹងអង្គភាពអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនដែលពាក់ព័ន្ធ ។

៤.៣-បន្តពង្រឹងនិងពង្រីកយន្តការបណ្តុះបណ្តាលមន្ត្រីអនុវត្តដោយកុំព្យូទ័រ ។

៤.៤-ពង្រឹងនិងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

៤.៥-សហការជាមួយUNODC ដើម្បីបង្កើតប្រព័ន្ធផ្តល់ព័ត៌មានឆាប់រហ័សសំរាប់តាមដាននូវការប្រគល់អោយដោយមានការឃ្លាំមើលឬករណីសង្ស័យផ្សេងៗ ។

៤.៦-សំរបសំរួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីពង្រឹងការត្រួតពិនិត្យនិងការគ្រប់គ្រងសារធាតុគីមីផ្សំដែលបាននាំចូល ប្រើប្រាស់ ស្តុកទុក លក់ចែកចាយដោយសហគ្រាសឬក្រុមហ៊ុន ។

៤.៧-សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីជំរុញអោយមានការចូលរួមជាសាធារណៈក្នុងការរាយការណ៍អំពីព័ត៌មានដែលទាក់ទងទៅនឹងការជួញដូរ ការផលិត ការស្តុកទុក និង ការប្រើបំពានគ្រឿងញៀន ។

៤.៨-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងត្រូវមានមេធាវីជាតំណាងផ្លូវច្បាប់ ។

៤.៩-សហការជាមួយUNODC និងដៃគូផ្សេងៗ ក្នុងការលើកកំពស់សមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀនរបស់ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

**៥-នីតិកម្ម :**

៥.១-សហការជាមួយក្រសួងយុត្តិធម៌ រៀបចំកម្មវិធីផ្សព្វផ្សាយដល់បណ្តាក្រសួង-ស្ថាប័នគ្រប់លំដាប់ថ្នាក់ អង្គការក្រៅរដ្ឋាភិបាល សហគមន៍ អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥.២-ជំរុញការរៀបចំនិងអនុវត្ត អនុក្រឹត្យ គោលនយោបាយ ប្រកាស និងសារាចរស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥.៣-តាមដានការអនុវត្តច្បាប់-អនុក្រិត្យ-ប្រកាសស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៦-ការព្យាបាល ស្តារនីតិសម្បទា និង ការធ្វើសមាហរណកម្ម :**

៦.១-សហការជាមួយ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច និង ស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្តគោលនយោបាយ និង យុទសាស្រ្តស្តីពីការព្យាបាល ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

៦.២-សហការជាមួយ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អង្គការសហប្រជាជាតិ អាជ្ញាធរមូលដ្ឋាន ប្រទេសម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ ក្នុងការពង្រឹងមជ្ឈមណ្ឌលព្យាបាល និងពង្រីកបន្ថែមមជ្ឈមណ្ឌលនេះនៅតាមខេត្តក្រុងអាទិភាព ។

៦.៣-សហការជាមួយUNODC ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងប្រទេសម្ចាស់ជំនួយ ដើម្បីបណ្តុះបណ្តាលជំនាញផ្សេងៗសំរាប់ដំណើរការមជ្ឈមណ្ឌល ។

៦.៤-រៀបចំអោយមានការប្រជុំក្រុមការងារបច្ចេកទេស ដើម្បីត្រួតពិនិត្យនិងកែសំរួល
លើខ្លឹមសារឯកសារបណ្ដុះបណ្ដាល ។

៦.៥-ពង្រឹងសមត្ថភាពបច្ចេកទេសដល់បុគ្គលិករបស់មជ្ឈមណ្ឌល ។